**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ផែនការយុទ្ធសាស្ត្រសំដៅស្រូបយកនិស្សិត ចាប់ពីឆ្នាំសិក្សា ២០០៧-២០០៨

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច **សភនវស** គឺជាគ្រឹះស្ថានឧត្តមសិក្សាដែលបានបង្កើតមុនគេបង្អស់នៅក្នុងប្រទេសកម្ពុជា ។ បច្ចុប្បន្ននេះ សាកលវិទ្យាល័យមានមហាវិទ្យាល័យចំនួន ៤ គឺ មហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យរដ្ឋបាលសាធារណៈ មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងគ្រប់គ្រង មហាវិទ្យាល័យសេដ្ឋកិច្ចពតិមានវិទ្យា និង ថ្នាក់ក្រោយបរិញ្ញាប័ត្រដែលធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ និង ថ្នាក់បណ្ឌិត ។ ក្រៅពីនេះ សាកលវិទ្យាល័យមានការិយាល័យចំនួន ៥ ដើម្បីដំណើរការផ្នែករដ្ឋបាល និង ដេប៉ាតឺម៉ង់ ចំនួន ៦ សំរាប់គ្រប់សាស្ត្រាចារ្យ និង ពិនិត្យមើលកម្មវិធីសិក្សានានា ។ បន្ថែមលើនេះ ដើម្បីអោយនិស្សិតកាន់តែមានចំណេះដឹងទូលំទូលាយក្នុងការសិក្សាស្រាវជ្រាវ និង ការសិក្សាភាសាបរទេសបន្ថែមទៀតនោះ សាកលវិទ្យាល័យក៏មានមជ្ឈមណ្ឌលស្រាវជ្រាវចំនួន ២ គឺ មជ្ឈមណ្ឌលស្រាវជ្រាវផ្នែកនីតិសាស្ត្រ មជ្ឈមណ្ឌលស្រាវជ្រាវផ្នែកសេដ្ឋកិច្ច និង គ្រប់គ្រង និង វិទ្យាស្ថានភាសាអង់គ្លេស ។

មជ្ឈមណ្ឌលស្រាវជ្រាវទាំងពីររបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងដោយមានការរួមដៃគ្នាពីសំណាក់ភាគីសហប្រតិបត្តិការបារាំងប្រចាំសាកលវិទ្យាល័យ ក្នុងគោលដៅលើកកំពស់គុណភាពអប់រំនិងសមត្ថភាពរបស់សាស្ត្រាចារ្យ និង និស្សិត តាមរយៈការស្រាវជ្រាវ និង បោះផ្សាយសៀវភៅ អត្ថបទ ព្រឹត្តប័ត្រស្រាវជ្រាវនានា ដែលទាក់ទងនឹងការសិក្សាទ្រឹស្តី បញ្ហារបច្ចុប្បន្នភាពនៃជីវភាពសង្គម ក៏ដូចជាការអនុវត្តន៏លើវិស័យច្បាប់ និងសេដ្ឋកិច្ច ។

បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច អាចចាត់ទុកជាបណ្ណាល័យដ៏ល្អមួយនៅក្នុងចំណោមបណ្តាសាកលវិទ្យាល័យនានា ។ បណ្ណាល័យនេះបានប្រមូលផ្តុំនូវសៀវភៅប្រមាណជាង ១ ម៉ឺន មុខដោយក្នុងនោះរួមមាននូវសៀវភៅ ទស្សនាវដ្តី និង សារពតិមាន ។ បណ្ណាល័យបើកអោយនិស្សិត សាស្ត្រាចារ្យ និង សាធារណជនទូទៅចូលអាន ។ បណ្ណាល័យ សភនវស គឺជាកន្លែងអាន កន្លែងសិក្សាស្រាវជ្រាវ ជាពិសេសជាកន្លែងសំរាប់និស្សិតធ្វើកិច្ចការដែលសាស្ត្រាចារ្យដាក់អោយ ។

***សភនវស*** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល គោលនយោបាយរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាព ភាគច្រើនជាតស្សរជនជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាលបច្ចុប្បន្ន ។ ក្រៅពីក្រុមប្រឹក្សាភិបាលដែលជាអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ សាកលវិទ្យាល័យក៏មានស្រាប់នូវក្រុមប្រឹក្សាផ្ទៃក្នុងចំនួនបីទៀតគឺ ក្រុមប្រឹក្សាវិន័យ ក្រុមប្រឹក្សាគរុកោសល្យ និង ក្រុមប្រឹក្សាបណ្ឌិតវិទ្យាសាស្ត្រ។

សភនវស ស្ថិតនៅតាមបណ្តោយផ្លូវមុនីវង្សដែលជាទីតាំងមួយដ៏ល្អ ស្អាត មានទីធ្លាធំទូលាយ យានយន្តធំទូលាយងាយស្រួលសំរាប់និស្សិតក្នុងការធ្វើដំណើរមកសិក្សា និង មានអាគារ និង ថ្នាក់រៀនធំទូលាយដែល បំពាក់សំភារៈសិក្សាទំនើប ។ ដោយសារកិត្តិនាម និង ការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំសាកលវិទ្យាល័យ យើងសង្កេតឃើញថាពីមួយឆ្នាំទៅមួយឆ្នាំចំនួននិស្សិតចុះឈ្មោះចូលរៀនមានចំនួនកើនជាលំដាប់គួរអោយកត់សំគាល់ ។ រហូតមកដល់ បច្ចុប្បន្ននេះ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅតែរក្សាឋានៈជាគ្រឹះស្ថានឧត្តមសិក្សាជាតិឈានមុខគេនៅក្នុងវិស័យច្បាប់ សេដ្ឋកិច្ច និង ពាណិជ្ជកម្ម ។

ដើម្បីរក្សាឋានៈជាគ្រឹះស្ថានឧត្តមសិក្សាជាតិឈានមុខគេ សាកលវិទ្យាល័យបានដាក់ចេញនូវផែនការជាយុទ្ធសាស្ត្រក្នុងការស្រូបយកនិស្សិតចូលរៀននៅថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដោយធ្វើការកំណត់នូវបេសកកម្ម គោលដៅ និង ទស្សនៈវិស័យ មួយច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព ។ ផែនការយុទ្ធសាស្ត្រនេះសំដៅអភិវឌ្ឍសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច អោយមានគុណភាពអប់រំខ្ពស់តាមក៏រិតប្រហាក់ប្រហែលទៅនឹងសាកលវិទ្យាល័យនានានៃបណ្តាប្រទេសក្នុងតំបន់។ ក្នុងនោះដោយផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍកំណែទំរង់កម្មវិធីសិក្សា សេវាកម្មនិស្សិត វិធីសាស្ត្របង្រៀនរបស់សាស្ត្រាចារ្យ ដំណើរការរដ្ឋបាល ការគ្រប់គ្រងបណ្ណាល័យ ការចុះឈ្មោះចូលរៀន ជាពិសេសចំពោះថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដែលបាននិងកំពុងអនុវត្តន៏ចាប់តាំងពីឆ្នាំសិក្សា២០០៥-២០០៦ មកដល់ពេលនេះ។

## **១-បេសកកម្ម**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានយកចិត្តទុកដាក់ និង ខិតខំប្រឹងប្រែងក្នុងការផ្តល់ដល់និស្សិតនូវការអប់រំដែលប្រកបដោយគុណភាពខ្ពស់ស្របតាមស្តង់ដារជាតិ និង នៅក្នុងតំបន់ដើម្បីអោយនិស្សិតមានចំណេះដឹង ចេះធ្វើការវិភាគប្រកបដោយប្រសិទ្ធភាព និង ជួយបណ្តុះបណ្តាលធនធានមនុស្សសំរាប់បំរើការងារនៅក្នុងវិស័យសាធារណៈ ។ សាកលវិទ្យាល័យលើកទឹកចិត្ត និង បំពេញសេចក្តីត្រូវការរបស់និស្សិតដោយផ្តល់អោយគេនូវមុខវិជ្ជាសិក្សាជាច្រើនដែលថ្មីសំរាប់និស្សិតថ្នាក់បរិញ្ញាប័ត្រ ថ្នាក់បញ្ញាប័ត្រជាន់ខ្ពស់ និង ថ្នាក់បណ្ឌិត និង ថ្នាក់ហ្វឹកហ្វឺនភាសាបរទេសជាដើម។ កម្មវិធីសិក្សាដែលសំរាប់អោយនិស្សិតមានលទ្ធភាពបំរើការនៅក្នុងវិស័យឯកជនត្រូវបានបង្កើត និង ត្រូវបានទទួលស្គាល់ ។ ពីមួយឆ្នាំទៅមួយឆ្នាំ សាកលវិទ្យាល័យមានមោទនៈភាពក្នុងការបណ្តុះបណ្តាលធនធានមនុស្សឆ្នើម ៗ សំរាប់វិស័យសាធារណៈ និង ឯកជន ។

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចផ្សព្វផ្សាយនូវចំណេះដឹងវិស័យច្បាប់ វិស័យសេដ្ឋកិច្ច និង ពាណិជ្ជកម្មដល់និស្សិត និង មន្ត្រីរាជការ ដើម្បីអោយពួកគេយកចំណេះដឹងទាំងនោះទៅជួយកសាងប្រទេសជាតិអោយបានរីកចំរើន ។ ជាពិសេស រៀបចំនិស្សិតដើម្បីអោយក្លាយខ្លួនជាអ្នកមានសមត្ថភាព និង ជំនាញមួយជាក់លាក់ដើម្បីបំរើការងារនៅក្នុងសង្គម ។ សភនវស គាំទ្រដល់បណ្តាសាស្ត្រាចារ្យដែលបានធ្វើការស្រាវជ្រាវយ៉ាងសកម្មដែលបាននាំមកនូវអ្វី ៗ ដែលថ្មី និង ប្លែកដើម្បីដាក់បញ្ចូលក្នុងការបង្រៀនដែលឆ្លើយតបបាននូវសេចក្តីត្រូវការរបស់និស្សិត ។

ក្រៅពីការបណ្តុះបណ្តាលធនធានមនុស្សសំរាប់សង្គមកម្ពុជា សាកលវិទ្យាល័យមានតួនាទីគឺជាច្រកអន្តរជាតិសំរាប់ដោះដូរចំណេះដឹងថ្មី ៗ ជាមួយពិភពខាងក្រៅ ។ តួនាទីនេះត្រូវបានបង្ហាញតាមរយៈការធ្វើសហប្រតិបត្តិការជាមួយបណ្តាសាកលវិទ្យាល័យដៃគូរបរទេសនានា និង តាមរយៈការផ្តល់អាហារូបករណ៏ជូននិស្សិតឆ្នើម ៗ ទៅបន្តការសិក្សានៅបរទេស។ ជាក់ស្តែងកន្លងមក សាកលវិទ្យាល័យតែងតែឈានមុខគេជានិច្ចនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយសាកលវិទ្យាល័យជាច្រើននៅបរទេសតាមរយៈការផ្លាស់ប្តូរសាស្ត្រាចារ្យ និង និស្សិត ។ ក្នុងឆ្នាំសិក្សា ២០០៧-២០០៨ នេះសាកលវិទ្យាល័យបញ្ជូននិស្សិតចំនួន ៧២ នាក់ ទៅសិក្សានៅបរទេស។ ទន្ទឹមនឹងការរីកចំរើនយ៉ាងគំហុកផ្នែកបច្ចេកវិទ្យានៅក្នុងសម័យកាលសាកលភាវូបនីយកម្ម បច្ចុប្បន្ននេះតំរូវការនៃការទទួលស្គាល់គុណភាព និង តំរូវការចុះឈ្មោះចូលរៀននៅឧត្តមសិក្សាអោយបានបរិមាណច្រើន ហើយជំនាញប្លែក ៗ តែមានគុណភាពគឺជារបត់មួយទៀតដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច និង សង្គមកិច្ច ។ ហេតុដូចនេះហើយ បានជារៀងរាល់ឆ្នាំសាកលវិទ្យាល័យបានកំណត់ឡើងវិញនូវបេសកកម្មរបស់ខ្លួនអោយច្បាស់លាស់ និង រៀបចំកម្មវិធីសិក្សាបានល្អ ។

## ២- គោលដៅ

រាជរដ្ឋាភិបាលទទួលស្គាល់ថា ចាំបាច់ត្រូវតែកែលំអអោយមានប្រសិទ្ធភាព នូវស្ថាប័នឧត្តមសិក្សា ។ ផ្នែកមួយចំនួនត្រូវបានកំណត់ថា ចាំបាច់ត្រូវដោះស្រាយជាបន្ទាន់ដើម្បីអោយការអប់រំក្រោយមធ្យមសិក្សាទទួលបានលទ្ធផលខ្ពស់ហើយអាចជាជំនួយដល់ដំណើរការអភិវឌ្ឍន៏សង្គម ។ ផ្នែកទាំងអស់នោះរួមមាន ការកែលំអកម្មវិធីសិក្សា វិធីសាស្ត្របង្រៀនរបស់សាស្ត្រាចារ្យ ដំណើរការរដ្ឋបាល និង មូលដ្ឋានសំភារៈ អោយមានប្រភពធនធានបានល្អជាងមុន និង សមស្របទៅនឹងសេចក្តីត្រូវការសេដ្ឋកិច្ចទីផ្សារ ។ ដោយយល់អំពីគោលដៅជាអាទិភាពរបស់រាជរដ្ឋាភិបាល សាកលវិទ្យាល័យបានដាក់ចេញជាផែនការយុទ្ធសាស្ត្រដោយធ្វើការកំណត់ជាគោលដៅសំខាន់ ៗ សំរាប់ដំណើរកាសាកលវិទ្យាល័យទាំងមូលអោយមានភាពរលូនដូចខាងក្រោម :

- ខិតខំធ្វើការបណ្តុះបណ្តាលនិស្សិតអោយមានចំណេះដឹងទូលំទូលាយ និង ធ្វើយ៉ាងណាអោយនិស្សិតដែលបានបញ្ចប់ការសិក្សាមានសមត្ថភាពពេញលេញ និង គុណភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារសំរាប់ការអភិវឌ្ឍន៏សេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រទេសជាតិ ។
- កសាងជួរអ្នកគ្រប់គ្រងប្រកបដោយសមត្ថភាព ដើម្បីរួមចំណែកក្នុងភារកិច្ចអភិវឌ្ឍន៏ប្រទេសជាតិ ជាពិសេសគឺបង្កលក្ខណៈសមស្របដល់និស្សិតក្នុងការប្រឡងប្រជែងចូលក្របខ័ណ្ឌនៃមុខងារសាធារណៈ, វិជ្ជាជីវៈតុលាការ,

វិជ្ជាជីវៈសេដ្ឋកិច្ច ដើម្បីក្លាយទៅជាអ្នកគ្រប់គ្រង : គ្រប់គ្រងរដ្ឋ, គ្រប់គ្រងដែនដី, គ្រប់គ្រងក្នុងគ្រឹះស្ថានសាធារណៈ គ្រប់គ្រងក្រុមហ៊ុន និងអង្គការក្រៅរដ្ឋាភិបាល ។

-តម្រង់ទិសចំណេះដឹង ជំនាញបច្ចេកទេស ទៅរកទីផ្សារការងារ : ក្រុមហ៊ុន, អង្គការនានា ក្នុងស្រុក ឬ អាចប្រកបវិជ្ជាជីវៈផ្សេងៗទៀតដូចជា : មេធាវី, ទីប្រឹក្សា, អ្នកជំនាញការ ជំនួយការអ្នកច្បាប់ឬជំនួយការអ្នកសេដ្ឋកិច្ច ឬមួយក៏អាចវិលទៅប្រកបការងារ ដើមពីមុនរបស់គេ ។

-ខិតខំអភិវឌ្ឍសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វិវត្តន៍ជាបណ្តើរៗ ឈានទៅកាន់ស្តង់ដារអប់រំមួយខ្ពស់ប្រហាក់ប្រហែលនឹងគ្រឹះស្ថានឧត្តមសិក្សានានាក្នុងតំបន់ ។

-បណ្តុះបណ្តាល និងបង្កើនសមត្ថភាពជូរសាស្ត្រាចារ្យ បង្កើនការធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិនានា ដើម្បីស្រូបយកនិស្សិតអោយបានលើសពី ៥០០ នាក់ ដែលសមស្របទៅនិងធនធានរបស់ ស.ភ.ន.វ.ស និងដើម្បីទាក់ទងសុំអាហារូបករណ៏ចេញទៅបរទេសឱ្យបានកាន់តែច្រើន ។

## ៣-ទស្សនៈវិស័យអភិវឌ្ឍន៍

សាកលវិទ្យាល័យមានភារកិច្ចបណ្តុះបណ្តាលធនធានមនុស្ស បំរើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ផ្តល់នូវចំណេះដឹងវិទ្យាសាស្ត្រទំនើបទាន់ការវិវត្តន៍នៃសេដ្ឋកិច្ចទីផ្សារ និង មានកិត្តិស្តង់ដារអន្តរជាតិ ជាពិសេស បណ្តាប្រទេសក្នុងតំបន់។ ថ្នាក់ដឹកនាំសាកលវិទ្យាល័យតែងតែគិតគូរ និង កំណត់នូវទស្សនៈវិស័យធំ ៧ ដូចជាការពង្រីកអាគារសិក្សាដើម្បីស្រូបយកនិស្សិត គុណភាពសិក្សា ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាលសាស្ត្រាចារ្យ សេវាកម្មនិស្សិត និង ដំណើរការរដ្ឋបាលដែលប្រកបដោយភាពរលូន ។ ការដាក់ចេញនូវទស្សនៈវិស័យជាគន្លឹះនេះ វាមានសារៈសំខាន់សំរាប់ជាត្រីវិស័យមួយជួយសាកលវិទ្យាល័យទាំងមូលក្នុងការអភិវឌ្ឍន៍របស់ខ្លួន ។ ចំណុចសំខាន់ ៧ មានដូចខាងក្រោម :

-ធ្វើការសិក្សាវិភាគអំពីការវិវត្តន៍នៃសេដ្ឋកិច្ច និង រៀបចំការសិក្សាស្រាវជ្រាវពត៌មានពីតំរូវការប្រើប្រាស់ជាក់ស្តែងរបស់សហគ្រាស ក្រុមហ៊ុន ស្ថាប័ន និង អង្គការនានាដែលត្រូវការធនធានមនុស្សដើម្បីតម្រង់ទិសនិស្សិតឱ្យចំតាមវិជ្ជាជីវៈនិមួយៗ និងស្របតាមទិសដៅនៃតម្រូវការទីផ្សារ ជាពិសេស ដើម្បីរកការងារអោយនិស្សិតដែលបានបញ្ចប់ការសិក្សាមានការងារធ្វើ ។

-ពង្រឹងគុណភាពអប់រំដោយបើកចំហទៅរកពិភពខាងក្រៅ ជាពិសេសគឺធ្វើទំនាក់ទំនង និងបង្កើន កិច្ចសហប្រតិបត្តិការជាមួយបណ្តាគ្រឹះស្ថានសិក្សាបរទេសនានា និងក្នុងតំបន់ ក៏ដូចជាអង្គការអន្តរជាតិនានា ដើម្បីទទួលយកបទពិសោធន៏ និងធ្វើបច្ចុប្បន្នភាពកម្មចំណេះដឹងឱ្យទាន់សម័យកាល ។

-កែលំអគុណភាពសិក្សាក្នុងនោះមាន ការជ្រើសរើសនិស្សិតចូលរៀន ការអភិវឌ្ឍកម្មវិធីសិក្សា ការប្រឡង ការសរសេរសារណា និក្ខេបបទបញ្ចប់ការសិក្សា ។

-កសាងបន្ថែមចំនួនសាស្ត្រាចារ្យថ្មី បណ្តុះបណ្តាលបន្តនូវសាស្ត្រាចារ្យចាស់ ព្រមទាំងធ្វើវិក្រឹត្យការជូរសាស្ត្រាចារ្យដែលមានស្រាប់គ្រប់ផ្នែក : សាស្ត្រចារ្យថ្នាក់រួម ថ្នាក់អនុវត្ត ថ្នាក់ភាសា ។

-អប់រំនិស្សិតមានចំណេះដឹងកាន់តែទូលំទូលាយ និងសំរបខ្លួនទៅនឹងការវិវត្តន៍ និង ផ្លាស់ប្តូរមិនឈប់ឈរនៃសង្គម ដើម្បីទទួលបានជោគជយ័ក្នុងទីផ្សារការងារនៅពេលអនាគត។

-បន្តពង្រឹង និង ពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូរដោយធ្វើការចងសម្ព័ន្ធភាពជាមួយគ្រឹះស្ថានសិក្សាបរទេស សមាគមសិក្សានានា នៅក្រៅប្រទេសដើម្បីផ្តល់ជូនដល់និស្សិត សាស្ត្រាចារ្យ បុគ្គលិកសិក្សា ធ្វើកាផ្លាស់ប្តូរ បទពិសោធន៍លើវិស័យសិក្សាថ្នាក់ឧត្តម ។

-ត្រួតពិនិត្យកម្មវិធីសិក្សាជាប្រចាំ និង បន្តអនុវត្តប្រព័ន្ធក្រេឌីតឱ្យកាន់តែសុក្រឹត ដើម្បីធានាបាននូវស្តង់ដារ គុណភាពមួយជាកំណត់ដែលមានលក្ខណៈឆ្លើយតបតម្រូវការអភិវឌ្ឍន៍ តាមទិសដៅទីផ្សារការងារព្រមទាំង បង្កលក្ខណៈទន់ភ្លន់ និង លក្ខណៈងាយស្រួលដល់ការផ្ទេរការសិក្សារបស់និស្សិតពីជំនាញមួយទៅជំនាញមួយ ទៀត និង ពីស្ថាប័នសិក្សាមួយទៅស្ថាប័នមួយទៀតរបស់និស្សិត។

បន្ថែមលើទស្សនៈវិស័យជាគោលធំ ៧ ដែលបានធ្វើការកំណត់ខាងលើ សាកលវិទ្យាល័យបានដាក់ចេញជាលំអិតនូវ ទស្សនៈវិស័យចាំបាច់មួយចំនួនដើម្បីអោយការអនុវត្តន៍កាន់តែមានប្រសិទ្ធភាព និង ទទួលបានផលល្អ។ ចំណុចសំខាន់ ៧ មានដូចខាងក្រោមៈ

-រៀបចំធ្វើសិក្ខាសាលា, សន្និសីទ, ការជួបជុំនានា ដោយរិះរកប្រធានបទសំខាន់ៗ ទាក់ទងទៅនឹងចំណេះដឹង និងចំណេះធ្វើស្របតាមតម្រូវការសង្គម ។

-ខិតខំបំពាក់សំភារៈឧបទេស បរិក្ខា និង មធ្យោបាយចាំបាច់នានា សំដៅធ្វើឱ្យការបណ្តុះបណ្តាល ក៏ ដូចជាការ សិក្សាស្រាវជ្រាវមានលក្ខណៈកាន់តែទំនើប និងប្រកបដោយប្រសិទ្ធិភាព ។

-បន្តកសាងជួរសាស្ត្រចារ្យឱ្យមានចំណេះដឹងកំរិតខ្ពស់ ដោយជំរុញលើកទឹកចិត្តការបណ្តុះបណ្តាលនៅនិងកន្លែងផង និងបញ្ជូនទៅបន្តការសិក្សានៅបរទេសផង ជាក់ស្តែងបច្ចុប្បន្នមានយុវសាស្ត្រាចារ្យចំនួន ២១នាក់ កំពុងសិក្សា ស្រាវជ្រាវនិក្ខេបបទថ្នាក់បណ្ឌិត ជាមួយសាកលវិទ្យាល័យនៃប្រទេសនានា។ តាមរយៈនេះ សាកលវិទ្យាល័យ នឹងមានជួរសាស្ត្រាចារ្យដែលមានសញ្ញាប័ត្របណ្ឌិតពីចំនួន ១៥ ដល់ ២៥ នាក់ នៅឆ្នាំ ២០០៩។

-ធ្វើវិក្រឹត្យការសាស្ត្រាចារ្យគ្រប់កំរិតតាមជំនាញនិមួយៗ តាមរយៈការរៀបចំធ្វើសិក្ខាសាលា ឬ វគ្គបំប៉នខ្លីៗ។

-រៀបចំរចនាសម្ព័ន្ធថ្មីរបស់សាកលវិទ្យាល័យ ដោយពង្រឹងរបៀបរបបការងារ និង បណ្តុះបណ្តាលជួរបុគ្គលិកដើម្បី ឱ្យយល់ពីតួនាទីរបស់ខ្លួន ហើយបំពេញការងារឱ្យមានប្រសិទ្ធិភាព និងការទទួលខុសត្រូវខ្ពស់ ដោយធ្វើការ ពិនិត្យឡើងវិញលើប្រាក់ឧបត្ថម្ភប្រចាំខែឱ្យស្របទៅនិងទំហំភារកិច្ចដែលគេម្នាក់ៗបានរ៉ាប់រងនិងទទួលខុសត្រូវ។

-រៀបចំដេប៉ាតឺម៉ង់ទាំង ៦ នៅក្នុងសាកលវិទ្យាល័យ និង ជួរសាស្ត្រាចារ្យរបស់មហាវិទ្យាល័យនិមួយៗ ឱ្យមាន ដំណើរការល្អ និង ប្រកបដោយប្រសិទ្ធិភាព ក្នុងនោះចំពោះមុខគឺយកចិត្តទុកដាក់គិតគូររៀបចំដេប៉ាតឺម៉ង់ថ្នាក់ ឆ្នាំសិក្សាមូលដ្ឋានឱ្យដំណើរការបានរលូនល្អ ដើម្បីស្រូបយកនិស្សិតអោយបានច្រើន។

-បង្កើនចំនួនអាហារូបករណ៍បន្ថែមទៀត ដើម្បីឱ្យនិស្សិតបានទៅបន្តការសិក្សានៅបរទេសកាន់តែច្រើន ជាពិសេស

គឺនៅគ្រឹះស្ថានឧត្តមសិក្សាជាដៃគូរបរទេសដែលមានស្រាប់ ។

-ធ្វើទំនាក់ទំនងជាមួយសាលាភូមិន្ទរដ្ឋបាល សាលាភូមិន្ទចៅក្រម សាលាបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីតម្រង់ទិសនិស្សិតដែលសិក្សាផ្នែកច្បាប់ទៅរកវិជ្ជាជីវៈរបស់ខ្លួនម្នាក់ៗ ។

-សាងសង់បន្ថែមនូវអគារសិក្សា បន្ទប់សិក្សាដើម្បីងាយស្រួលដល់ដំណើរការសិក្សារបស់និស្សិត ។

-ពង្រីកបណ្ណាល័យដែលមានស្រាប់ ដើម្បីអោយមានកន្លែងអង្គុយអានកាន់តែច្រើនថែមទៀតសំរាប់និស្សិត។ ក្នុងនោះបំពាក់សៀវភៅសិក្សា ទស្សនាវដ្តី កាសែត ឯកសារពាក់ព័ន្ធនានាសំរាប់អោយនិស្សិតចូលអាន ។

-បន្តរៀបចំ និងកែលំអចំណតយានយន្តឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយល្អ ។

-ពង្រីកទីលានកីឡារួមដែលមានស្រាប់ដូចជា : ទីលានវាយសី វាយប៊ូល វាយកូនឃ្លីលើតុ និង កសាងបន្ថែមទីលានបាល់បោះ បាល់ទះ ដើម្បីឱ្យនិស្សិត សាស្ត្រាចារ្យហាត់ និង ប្រកួត សំដៅបង្កើនសុខភាពខាងរាងកាយ និងលើកទឹកចិត្តការប្រកួតជាអន្តរសាកលវិទ្យាល័យ ។

-រកថវិកាដើម្បីរៀបចំបកប្រែជាបណ្តើរៗ នូវសៀវភៅបរទេសដែលចាំបាច់មកជាភាសាជាតិ ដើម្បីឱ្យនិស្សិតងាយសិក្សាស្រាវជ្រាវ ។ ទន្ទឹមនឹងនេះ រៀបចំបង្កើតសន្ទានុក្រមពាក្យច្បាប់ និង ពាក្យសេដ្ឋកិច្ចដើម្បីឱ្យនិស្សិត សាស្ត្រាចារ្យ ក៏ដូចជាអ្នកស្រាវជ្រាវទូទៅប្រើប្រាស់ជាប្រយោជន៍រួម ។

-បន្តកិច្ចសហការជាមួយដៃគូបរទេសនានា ដើម្បីលើកកំពស់ការសិក្សាភាសាបរទេស : អង់គ្លេស បារាំង ជប៉ុន និង កូរ៉េ ដល់និស្សិតដើម្បីជាយានសំខាន់សំរាប់ទទួលអាហារូបករណ៍ទៅបន្តការសិក្សានៅបរទេស ក៏ដូចជាដើម្បីងាយស្រួលក្នុងការរកការងារធ្វើក្រោយពេលបញ្ចប់ការសិក្សា។

-ពង្រីកប្រព័ន្ធ Network និង រៀបចំប្រព័ន្ធរក្សាទិន្នន័យ (Data base) ដោយកុំព្យូទ័រលើការចុះឈ្មោះចូលរៀនរបស់និស្សិតដោយដាក់អោយមានជា លេខកូដកម្មវិធីសិក្សា មុខវិជ្ជាសិក្សាទាំងអស់ និង ប្រមូលគ្រប់ពត៌មានទាំងអស់ដើម្បីរក្សាទុកជាមូលដ្ឋានទិន្នន័យរបស់សាកលវិទ្យាល័យ ។

-រៀបចំបោះផ្សាយ សៀវភៅមគ្គុទេសក៍ និងព្រឹត្តិប័ត្រពត៌មានផ្សេងៗរបស់សាកលវិទ្យាល័យ ។

-បំពាក់ប្រព័ន្ធ Internet ឱ្យបានច្រើនដើម្បីអោយនិស្សិតងាយស្រួលសិក្សាស្រាវជ្រាវពត៌មានផ្សេង ៗ ។

តាមបទពិសោធន៍ដែលបានអនុវត្តជារៀងរាល់ឆ្នាំកន្លងមក សាកលវិទ្យាល័យយល់ឃើញថាផែនការយុទ្ធសាស្ត្រនេះនឹងពង្រឹងខ្លួនបានជាបណ្តើរៗ ជាពិសេសចំពោះមុខនេះ សាកលវិទ្យាល័យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្កើតដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានជាមួយកម្មវិធីសិក្សាថ្មីតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា និងគណៈកម្មធិការទទួលគុណភាពអប់រំនៃកម្ពុជា ។

ទន្ទឹមនឹងនេះ ដើម្បីជំរុញការអភិវឌ្ឍន៍ឱ្យកាន់តែឆាប់រហ័ស សាកលវិទ្យាល័យគ្រោងនឹងរៀបចំបង្កើតសមាគមមួយដែលសមាជិកគឺអ្នកជាអតីតនិស្សិតរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដើម្បីជួយរួម

ដៃជាមួយសាកលវិទ្យាល័យកសាងនូវមូលដ្ឋានសំភារៈ និង បង្កើតមធ្យោបាយថ្មី ៗ ថែមទៀតជាប្រយោជន៍រួមសំរាប់សាកលវិទ្យាល័យទាំងមូល ។

រហូតមកដល់ពេលនេះ យើងសង្កេតឃើញថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅតែរក្សាឋានៈជាគ្រឹះស្ថានឧត្តមសិក្សាជាតិឈានមុខគេនៅ ក្នុងវិស័យច្បាប់ សេដ្ឋកិច្ច និង ពាណិជ្ជកម្ម ដោយសារមានការគាំទ្រយ៉ាងច្រើនពីសំណាក់សាធារណជន ជាពិសេសអាណាព្យាបាលនិស្សិតជាច្រើនបានបញ្ជូនកូន-ចៅរបស់ពួកគេមកសិក្សានៅទីនេះ ។

ភ្នំពេញ. ថ្ងៃទី ខែ ឆ្នាំ ២០០៨

**សាកលវិទ្យាធិការ**

**<u>កន្លែងទទួល</u>**

-អគ្គលេខាធិការដ្ឋាន គ.ទ.ក

"ដើម្បីជូនជាសេចក្តីរាយការណ៍"

-អគ្គនាយកដ្ឋានឧត្តមសិក្សា

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ/ដេប៉ាតឺម៉ង់

ឆ្នាំសិក្សាមូលដ្ឋាន